# និន្នាការសេដ្ឋកិច្ចសង្គម

# Socio-Economic Trends

**ខែមេសា-ឧសភា ឆ្នាំ២០១៧**

**April - May 2017**

## មាតិកា


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប / Executive summary** | **២** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia economic trends** | **៥** |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index | ៥ |
| ១.២. វិស័យហិរញ្ញវត្ថុ / Finance | ៦ |
| ១.៣. វិស័យពាណិជ្ជកម្ម / Trade | ៧ |
| ១.៤. ការអនុវត្តថវិកា / Budget execution | ៨ |
| ១.៥. វិស័យវិនិយោគឯកជន / Private investment | ៩ |
| ១.៦. វិស័យទេសចរណ៍ / Tourism | ១០ |
| ១.៧. វិស័យសំណង់ / Construction | ១០ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ / International commodity prices** | **១១** |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price: Brent, WTI, Dubai) | ១១ |
| ២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) | ១១ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) | ១១ |
| **៣. ឧបសម្ព័ន្ធ** | **១៣** |

## ខ្លឹមសារសង្ខេប

១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញក្នុងខែមេសា ឆ្នាំ២០១៧ បានកើនឡើង ០,៤% ធៀបនឹងខែមុន និងបានកើនឡើង ៣,២% ធៀបនឹង១ឆ្នាំមុន។ ធៀបនឹងខែមីនាកន្លងទៅ សន្ទស្សន៍ថ្លៃនៃក្រុមទំនិញមួយចំនួនបានកើនឡើងគួរកត់សម្គាល់ ដូចជាសន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង, សន្ទស្សន៍ថ្លៃគ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់និងការថែទាំ, សន្ទស្សន៍ថ្លៃភោជនីយដ្ឋាន និងសន្ទស្សន៍ថ្លៃសម្លៀកបំពាក់និងស្បែកជើង។

បើធៀបនឹង១ឆ្នាំមុន សន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹងបានកើនឡើង ៣,៨% ដោយសារកំណើនថ្លៃសាច់ជ្រូក សាច់គោ សាច់មាន់ ត្រីនិងបន្លែ, សន្ទស្សន៍ថ្លៃភោជនីយដ្ឋានបានកើនឡើង ៤,១% និងសន្ទស្សន៍ថ្លៃការដឹកជញ្ជូនបានកើនឡើង ៥,៩% ក្នុងនោះថ្លៃប្រេងសាំងធម្មតានិងប្រេងម៉ាស៊ូតកើនឡើង ១៥,៥% និង១២,៦%។

២. *ឥណទាន និងអត្រាការប្រាក់៖* គិតត្រឹមខែមេសា ឆ្នាំ២០១៧ ឥណទានផ្តល់ដោយធនាគារពាណិជ្ជមានចំនួន ៥៩.៦៦៤ប៊ីលានរៀល បានកើនឡើង ៣,២% ធៀបនឹងខែមុន (កើនឡើង ១០,៣% បើធៀបនឹង១ឆ្នាំមុន), ក្នុងនោះឥណទានផ្តល់ដល់វិស័យសេវាកម្ម បានកើនឡើង ២,៧% និងឥណទានផ្តល់ដល់វិស័យសំណង់បានកើនឡើង ៦,៥%, ឥណទានផ្តល់ដល់រូបវន្តបុគ្គលនិងផ្សេងៗនៅតែបន្តកើនឡើងក្នុងខែមេសានេះ។

អត្រាការប្រាក់ឥណទាននៃធនាគារពាណិជ្ជបានថយចុះគួរកត់សម្គាល់ក្នុងរយៈពេល៣ខែចុងក្រោយនេះ, គិតត្រឹមខែមេសា ឆ្នាំ២០១៧ អត្រាការប្រាក់របស់ធនាគារពាណិជ្ជចំពោះឥណទានជាប្រាក់រៀលស្មើនឹង ១៤,៨៤% និងឥណទានជាប្រាក់ដុល្លារស្មើនឹង ១១,៦៤%, រីឯអត្រាការប្រាក់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(គ្រឹះស្ថាន៣ធំជាងគេ)ពុំមានការប្រែប្រួលគួរកត់សម្គាល់ទេ។ កត្តាកំណត់អត្រាការប្រាក់សំខាន់ៗនៃគ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជាមានដូចជា ចំណាយលើប្រភពមូលទុន ការប្រតិបត្តិការអាជីវកម្ម ឥណទានមិនដំណើរការ អតិផរណា និងប្រាក់ចំណេញ។

*អត្រាប្តូរប្រាក់៖* ប្រាក់រៀលបានថយចុះតម្លៃបន្តិចក្នុងខែឧសភា ឆ្នាំ២០១៧, គិតត្រឹមខែឧសភានេះ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារស្មើនឹង ៤.០៦៩រៀល/ដុល្លារ ដែលអត្រាខែមេសាស្មើ ៤.០៣៥រៀល/ដុល្លារ និងអត្រាខែមីនាស្មើ ៤.០០៥រៀល/ដុល្លារ។ ធនាគារជាតិកម្ពុជាអនុវត្តរបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង ដោយធ្វើអន្តរាគមលើទីផ្សារប្តូរប្រាក់ដើម្បីគ្រប់គ្រងនិងរក្សាស្ថិរភាពអត្រាប្តូរប្រាក់។ គិតត្រឹមខែមេសា ឆ្នាំ២០១៧នេះ ទុនបម្រុងជារូបិយប័ណ្ណបរទេសបានកើនឡើងដល់ ៧.៣៤៦លានដុល្លារ។ ក្នុងរយៈពេល៣ខែ ឆ្នាំ២០១៧នេះ ធនាគារជាតិបានធ្វើការទិញចូលនូវប្រាក់ដុល្លារចំនួន ១៥៩លានដុល្លារ។

*ការផ្គត់ផ្គង់រូបិយវត្ថុ៖* រូបិយវត្ថុទូទៅM2 បានបន្តកើនឡើងក្នុងដើមឆ្នាំ២០១៧នេះ គឺបានកើនឡើងប្រមាណ ១,៧% ក្នុង១ខែ ប៉ុន្តែសមាមាត្រប្រាក់រៀលធៀបនឹងរូបិយវត្ថុទូទៅM2 បានថយចុះជាបន្តបន្ទាប់។ គិតត្រឹមខែមេសា ឆ្នាំ២០១៧ រូបិយវត្ថុទូទៅM2 មានចំនួន ៦១.៧២៥ប៊ីលានរៀល បានកើនឡើង ១,៩% ធៀបនឹងខែមុន និងបានកើនឡើង ១៧,០% ធៀបនឹង១ឆ្នាំមុន ក្នុងនោះប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសបានកើនឡើង ២,១% ធៀបនឹងខែមុន និងបានកើនឡើង ១៩,៦% ធៀបនឹង១ឆ្នាំមុន។

*ផ្នែកទីផ្សារមូលបត្រ៖* នៅខែឧសភា ឆ្នាំ២០១៧ តម្លៃជួញដូរ(trade value) លើទីផ្សារមូលបត្រកម្ពុជា(CSX) មាន ៩២៩លានរៀល បានកើនឡើង ៦៥% ធៀបនឹងខែមេសាកន្លងទៅ, ក្នុងឆ្នាំ២០១៦កន្លងទៅ ជាមធ្យមមានតម្លៃជួញដូរ

៨៣៥លានរៀលក្នុង១ខែ។ ក្រុមហ៊ុនកំពង់ផែស្វយ័តក្រុងព្រះសីហនុបានបញ្ចប់ការធ្វើប៊ុកបៀលឌីងនិងសម្រេចបានថ្លៃ ៥.០៤០រៀលក្នុង១ភាគហ៊ុន, និងបានចាប់ផ្តើមទិញ-លក់លើទីផ្សារ(CSX)ជាផ្លូវការនៅថ្ងៃទី០៨ មិថុនា ២០១៧ ជាមួយថ្លៃនៅពេលបើកទីផ្សារ ៥.៣៦០រៀលក្នុង១ភាគហ៊ុន។

៣. *ការនាំចូល÷* ក្នុងខែមេសា ឆ្នាំ២០១៧ ការនាំចូលជាទឹកប្រាក់សរុប ១.០៧៦លានដុល្លារ បានថយចុះ ៧,៦% ធៀបនឹងខែមុន ក្នុងនោះការនាំចូលមុខទំនិញវាយនភ័ណ្ឌបានថយចុះ ៩,២% និងការនាំចូលមុខទំនិញប្រភេទផ្សេងៗបានថយចុះ ៦,៧%, រីឯការនាំចូលប្រេងឥន្ធនៈមានចំនួន ៦៩លានដុល្លារ បាននៅថេរធៀបនឹងខែមុន ប៉ុន្តែទាបជាងក្នុងឆ្នាំ ២០១៦កន្លងទៅដែលជាមធ្យមមានការនាំចូលប្រេងឥន្ធនៈ ១០៦លានដុល្លារក្នុងមួយខែ។ *ការនាំចេញ÷* ក្នុងខែមេសា ឆ្នាំ ២០១៧ ការនាំចេញគិតជាទឹកប្រាក់មានចំនួន ៦៨២លានដុល្លារ បានថយចុះ ២៣,៦% ធៀបនឹងខែកន្លងទៅ, ក្នុងនោះការនាំចេញវាយនភ័ណ្ឌនិងស្បែកជើងមានចំនួន ៤៧៤លានដុល្លារ បានថយចុះ ២៦,២% និងការនាំចេញអង្ករនិងកៅស៊ូក៏បានថយចុះគួរកត់សម្គាល់ផងដែរ។ រយៈពេល ៤ខែ ឆ្នាំ២០១៧នេះ ការនាំចូលសរុបមាន ៤.២៧៧លានដុល្លារ បានកើនឡើង ១១,០% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន និងការនាំចេញសរុបមាន ៣.២១៣លានដុល្លារ បានកើនឡើង ៣,៩%។

៤. ក្នុងខែមេសា ឆ្នាំ២០១៧ រដ្ឋបាលថ្នាក់ជាតិអនុវត្តចំណូលក្នុងប្រទេសសរុបដែលចំណូលទាំងអស់ជាប្រភេទចំណូលចរន្តចំនួន ១.៤៩៩ប៊ីលានរៀល បានកើនឡើង ១៣,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន គាំទ្រដោយចំណូលពន្ធលើប្រាក់ចំណេញ អាករលើតម្លៃបន្ថែម និងអាករពិសេស។ រដ្ឋបាលថ្នាក់ជាតិអនុវត្តចំណាយថវិការសរុប ៨២៧ប៊ីលានរៀល បានថយចុះ ១១,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន, ក្នុងនោះចំណាយចរន្តមានចំនួន ៦៣៦ប៊ីលានរៀល បានកើនឡើង ០,៨% និងចំណាយមូលធនមានចំនួន ១៩១ប៊ីលានរៀល បានថយចុះ ៣៧,៤%។ តុល្យភាពថវិកាចរន្តនៃខែមេសា ឆ្នាំ ២០១៧ មានអតិរេកសាច់ប្រាក់ ៨៦៣ប៊ីលានរៀល និងតុល្យភាពថវិកាសរុបមានអតិរេកសាច់ប្រាក់ ៦៧២ប៊ីលានរៀល។

ជារួមក្នុងរយៈពេល ៤ខែដើមឆ្នាំ២០១៧នេះ ចំណូលក្នុងប្រទេសសរុបអនុវត្តបានចំនួន ៥.៧៦១ប៊ីលានរៀល បានកើនឡើង ១៨,៨% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន (ខ្ពស់ជាងច្បាប់ថវិកា ៣,៨%), ចំណាយរដ្ឋបាលថ្នាក់ជាតិសរុបចំនួន ៣.៩៧៧ប៊ីលានរៀល បានកើនឡើង ២០,៤% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំកន្លងទៅ (ទាបជាងច្បាប់ថវិកា ១២,៩%) ដោយមានការកើនឡើងចំណាយសម្រាប់វិស័យការពារនិងសន្តិសុខជាតិនិងរដ្ឋបាលស៊ីវិល ពោលគឺការអនុវត្តមានលក្ខណៈល្អប្រសើរជាងឆ្នាំកន្លងទៅដោយសារកំណែទម្រង់ និងអ្នកអនុវត្តកាន់តែយល់ជ្រួតជ្រាបពីនីតិវិធីនានា។ ជាលទ្ធផលរយៈពេល៤ខែដើមឆ្នាំ២០១៧ តុល្យភាពថវិកាចរន្តមានអតិរេកសាច់ប្រាក់ ២.៨២២ប៊ីលានរៀល និងតុល្យភាពថវិកាសរុបមានអតិរេកសាច់ប្រាក់ ១.៧១៣ប៊ីលានរៀល។

៥. ក្នុងខែឧសភា ឆ្នាំ២០១៧នេះ ចំនួនគម្រោងវិនិយោគអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមាន ៧គម្រោង អាចបង្កើតការងារបានប្រមាណ ៧ពាន់នាក់ និងគិតជាទុនវិនិយោគ ១.០០៤លានដុល្លារ ក្នុងនោះមានគម្រោងវិនិយោគក្នុងវិស័យសេវាកម្មរបស់ក្រុមហ៊ុនចិនទៅលើព្រលានយន្តហោះអន្តរជាតិសៀមរាបដែលមានទុនវិនិយោគ ៩៦២លានដុល្លា។ ក្នុងរយៈពេល ៥ខែដើមឆ្នាំ២០១៧នេះ ចំនួនគម្រោងវិនិយោគអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមាន ៣៤គម្រោង គិតជាទុនវិនិយោគ ១.១៦៥លានដុល្លារ បានថយចុះ ៣៣% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនោះមានការថយចុះខ្លាំងនូវការវិនិយោគលើវិស័យកសិកម្ម ឧហ្សាហកម្មកម្មនិងទេសចរណ៍, រីឯវិនិយោគវិស័យសេវាកម្ម បានកើនឡើង ១៧៩%។

៦. ក្នុងខែមេសា ឆ្នាំ២០១៧ ចំនួនមកដល់នៃភ្ញៀវអន្តរជាតិមានប្រមាណ ៤១៣ពាន់នាក់ បានថយចុះ ១៣,៥% ធៀបនឹងខែមីនាកន្លងទៅ ប៉ុន្តែខ្ពស់ជាងខែដូចគ្នាឆ្នាំមុន ១២,៣%, ការថយចុះនេះមានលក្ខណៈជារដូវកាល ដែលជាទូទៅចំនួនមកដល់នៃភ្ញៀវអន្តរជាតិមានការថយចុះ បន្ទាប់ពីរដូវវិស្សមកាលនាតំបន់អាស៊ីភាគឦសាននិងតំបន់អឺរ៉ុបបានបញ្ចប់ ហើយចំនួននេះនឹងមានការប្រែប្រួលឬកើនឡើងតិចតួចរហូតដល់ខែកញ្ញាខាងមុខ។ ក្នុងរយៈពេល ៤ខែដើមឆ្នាំ២០១៧នេះ ចំនួនមកដល់នៃភ្ញៀវអន្តរជាតិសរុប ១.៩១៦ពាន់នាក់ បានកើនឡើង ១២,០% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៧. ចំនួនសំណើសាងសង់ប្រចាំខែមានការថយចុះជាបន្តបន្ទាប់នៅដើមឆ្នាំ២០១៧នេះ។ ក្នុងរយៈពេល ៥ខែដើមឆ្នាំ២០១៧ សំណើសាងសង់សរុបមាន ១.២៤០គម្រោង បានកើនឡើង ២៥០គម្រោងបើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន, ប៉ុន្តែបើគិតជាផ្ទៃក្រឡាសាងសង់សរុបមាន ៤.៨៧១ពាន់ម៉ែត្រការ៉េ គឺបានថយចុះ ៥១% និងគិតជាតម្លៃសាងសង់សរុប ៤.៣៦២លានដុល្លារ បានថយចុះ ៣៤%។

៨. *ថ្លៃប្រេងឆៅ* ក្នុងខែឧសភា ឆ្នាំ២០១៧ ថ្លៃប្រេងឆៅបន្តមានការប្រែប្រួលខ្លាំងដោយជារួមបានកើនឡើងក្នុង៣សប្តាហ៍ដំបូង និងបានថយចុះខ្លាំងក្នុងសប្តាហ៍ចុងក្រោយនៃខែ។ គិតត្រឹមខែឧសភា ប្រេងឆៅក្នុងកិច្ចសន្យាលក់១ខែខាងមុខប្រេងBrentថ្លៃ ៥០,៣ដុល្លារ/ធុង ប្រេងDubaiថ្លៃ ៥០,១ដុល្លារ/ធុង និងប្រេងWTIថ្លៃ ៤៨,៣ដុល្លារ/ធុង ជារួមបានថយចុះបន្តិចធៀបនឹងខែមេសាកន្លងទៅ។ ការថយចុះថ្លៃប្រេងឆៅនេះគឺបណ្តាលមកពីការផ្គត់ផ្គង់លើទីផ្សារពិភពលោកបានបន្តកើនឡើង, យោងតាមប្រភពទិន្នន័យរបស់EIA ផលិតកម្មប្រេងបានកើនឡើងដល់ ១.៤៤៨ធុង/ថ្ងៃក្នុងខែឧសភានៃឆ្នាំ២០១៧នេះ។

*ថ្លៃអង្ករ* ក្នុងខែឧសភា ឆ្នាំ២០១៧ *(១)អង្ករកម្ពុជា* អង្ករនាំចេញរបស់កម្ពុជា(ខ្ទេច៥%)ថ្លៃ ៤២០ដុល្លារ/តោន បាននៅថេរធៀបនឹងខែមុននិង១ឆ្នាំមុន។ *(២)អង្ករថៃ* អង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៤៣៨ដុល្លារ/តោន បានកើនឡើង ១៣,២% ធៀបនឹងខែមុន ប៉ុន្តែបានថយចុះ ១,២% ធៀបនឹង១ឆ្នាំមុន។ យោងតាមគេហទំព័រសមាគមន៍នាំចេញអង្ករថៃ កំណើនថ្លៃនេះគឺដោយសារមានកំណើនការបញ្ជាទិញពីប្រទេសចិន ភីលីពីននិងប្រទេសមួយចំនួននៅអាហ្វ្រិក។ *(៣)អង្ករវៀតណាម* អង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៣៧២ដុល្លារ/តោន បានកើនឡើង ៦,៣% ធៀបនឹងខែមុន និងបានកើនឡើង ១,៩% ធៀបនឹង១ឆ្នាំមុន, ការកើនឡើងនេះគឺដោយសារមានកំណើនតម្រូវការពីប្រទេសនាំចូលអង្ករសំខាន់ៗនៅអាស៊ី។

*ថ្លៃកៅស៊ូ* គិតត្រឹមខែឧសភា ឆ្នាំ២០១៧ កៅស៊ូស្តង់ដារSTR20ថ្លៃ ១.៦៤០ដុល្លារ/តោន បានថយចុះ ១០,៤% ធៀបនឹងខែមុន និងកៅស៊ូSGP/MYSថ្លៃ ២.១០០ដុល្លារ/តោន បានថយចុះ ៦,៣% ធៀបនឹងខែមុន។ សមាគមន៍ប្រទេសផលិតកៅស៊ូធម្មជាតិ(ANRPC) បានព្យាករណ៍បរិមាណផ្គត់ផ្គង់កៅស៊ូក្នុងឆ្នាំ២០១៧នេះមានចំនួន១២,៧៧លានតោន គឺនឹងកើនឡើង ៥,៧% ធៀបនឹងឆ្នាំមុន និងបរិមាណតម្រូវការមានចំនួន ១២,៨២លានតោន នឹងកើនឡើង ១,៨% ធៀបនឹងឆ្នាំ២០១៦កន្លងទៅ។

*(ចំពោះសេចក្តីលម្អិតនៃរបាយការណ៍ សូមទាក់ទងផ្ទាល់នាយកដ្ឋានស្ថិតិ នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)*

# ៣. ឧបសម្ព័ន្ធ

## សូចនាករនាំមុខ (Leading Indicators)




Source: Min. LMUC




Source: Ministry of Tourism




Source: Customs and Excise Dept.




Source: Customs and Excise Dept.




Source: MEF & Int.




Source: MEF & Int.

## អតិផរណានិងទុនបំរុងបរទេស (Inflation and Foreign Reserves)

**Net Foreign Reserve (Mn US$)**




Source: NBC

**Inflation (Montly)**




Source: NIS

**Inflation (Annual)**




Source: NIS

**Inflation of Main Group Items (monthly)**




Source: NIS

**Inflation of main group Items (Year on Year)**




Source: NIS

**Min-lending & 3month deposit Interest rate in Riel**




Source: NBC

# អត្រាប្តូរប្រាក់ (Exchange Rate)

**Exchange rate R/100Đ and R/B**




Source: IMF

**Exchang Rate Mal-Ringgit/$ and Phi-Peso/$**




Source: IMF

**CPI and Exchange rate R/$**




Source: IMF

**Exchange rate EU Euro/US$ and Pound/US$**




Source: IMF

**Exchange rate Aus-$ and HK-$**




Source: IMF

**Exchange rate Sing-$ and Yen-$**




Source: IMF

# វិស័យរូបិយវត្ថុ និងធនាគារ (Money and Banking)

**Liquidity in Bn-R and in % to GDP**




Source: NBC

**NFA and NDA (Bn-R)**




Source: NBC

**Credit to private sector, CPS (Stock) and growth**




Source: NBC

**Credit to Private Sectors by Sector (Bn-R)**




Source: NBC

**Currency outside bank, COB and foreign deposits, FD**




Source: NBC

**MFIs and NGOs Loans Outstanding**




Source: NBC

# ការអនុវត្តថវិកា (Budget)

**ចំណូលក្នុងប្រទេសនិងពន្ធលើពាណិជ្ជកម្ម ឆ្នាំ ២០១៦-២០១៧**




**ចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ឆ្នាំ២០១៦-២០១៧**




**ចំណាយចរន្ត និង វិនិយោគឆ្នាំ ២០១៦-២០១៧**




**ការដកសាច់ប្រាក់កម្ចីទ្វេភាគី និងពហុភាគី ឆ្នាំ ២០១៦-២០១៧**




**ចំណាយបៀវត្ស និង មិនមែនបៀវត្ស ឆ្នាំ ២០១៦-២០១៧**




Source: MEF

**ចំណាយការពារសន្តិសុខ និង រដ្ឋបាលស៊ីវិលឆ្នាំ ២០១៦-២០១៧**



# វិនិយោគឯកជន និង ការបង្កើតការងារ (Investment and Employment)


















# វិស័យពាណិជ្ជកម្ម (Trades)


















********

***រៀបចំដោយ***

***អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ***

***ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ***

*ព័ត៌មានផ្សេងៗ សូមទាក់ទង*

*ទូរស័ព្ទលេខ÷ ០២៣ ៤២៧៩១៣, ០៧៧ ៧០៣៤៣៦, ០៩៦ ៩៧៩១៦៨៦*

*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ ព្រឹក និង ២:០០ ដល់ ៥:០០ រសៀល*